**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០១៦

**សេចក្តីផ្តើម :**

នៅក្នុងខែវិច្ឆិកានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោមនេះ ៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:

### ១.មុខងារនីតិកម្ម:

| *វចនាសម្ព័ន្ធនយោបាយ* | *វចនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២ លើក និងប្រជុំពេញអង្គចំនួន០១ លើក ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៥ :<br>១.សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល<br>២.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី៧ ស្តីពីប្រព័ន្ធធ្វើងកាត់គយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពី កិច្ចសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ<br>៣.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារ ដើម្បីអនុវត្តកញ្ចប់ទី៦ នៃការប្តេជ្ញាបើកចំហរសេវាហិរញ្ញវត្ថុ នៅក្រោម | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក<br>- ប្រជុំក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យសិក្សាស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងសេចក្តីស្នើបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា សម្រាប់នីតិកាលទី៤<br>- ទទួលសេចក្តីព្រាងច្បាប់ចំនួន០២ច្បាប់ ពីរាជរដ្ឋាភិបាល និងបានចម្លងចែកជូនគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា<br>- ធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗចំនួន២៦ច្បាប់ |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវា<br>៤.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣<br>៥.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើត និងការអនុវត្តបញ្ជរតែមួយអាស៊ាន ពិធីសារស្តីពីការបង្កើត និងការអនុវត្តបញ្ជរតែមួយអាស៊ាន និងពិធីសារស្តីពីក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តបញ្ជរតែមួយអាស៊ាន<br>- គណៈកម្មការទី២ ប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៤ច្បាប់<br>- គណៈកម្មការទី៨ ប្រជុំជាមួយតំណាងក្រសួងសុខាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់ ។ | - បានធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា បញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- បានស្រាវជ្រាវអំពីនីតិវិធីក្នុងការតាក់តែងច្បាប់របស់សភាប្រទេសទាំង១០ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍<br>- បានកំពុងស្រាវជ្រាវធ្វើជំនួយស្មារតីអំពីការសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់<br>- បានផ្គត់ផ្គង់សម្ភារៈ ភេសជ្ជៈ និងអាហារសម្រន់ សរុបចំនួន០៧លើក អ្នកចូលរួមចំនួន៣៣៣នាក់ និងរៀបចំសាល បម្រើសេវាភេសជ្ជៈសរុបចំនួន០៦លើក មានអ្នកចូលរួមចំនួន១៨៩នាក់<br>- បានថតចម្លងឯកសារ សរុបចំនួន១៥សំណើរ (១.៥៦៩ច្បាប់) អស់ក្រដាសសរុបចំនួន១៨.២៧៩សន្លឹក<br>- ការពារ និងរៀបចំសណ្តាប់ធ្នាប់នៅពេលប្រជុំដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៧៧នាក់ ស្មើនឹង០៨លើក<br>- បានរៀបចំទីកន្លែងប្រជុំចំនួន១៣លើក ត្រួតពិនិត្យប្រព័ន្ធសំឡេង ម៉េក្រូហ្វូន កាមេរ៉ាវីដេអូសុវត្ថិភាពចំនួន១៣១លើក ថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មានចំនួន១៧លើក បង្ហោះលើគេហទំព័រព្រឹទ្ធសភា និងផលិតជា Video online ចំនួន៣៥លើក<br>- បញ្ជូនលិខិតទៅក្រៅស្ថាប័នព្រឹទ្ធសភាចំនួន០២ច្បាប់ |

| | |
|---|---|
| | - បានរៀបចំបែបបទ និងធ្វើកំណត់ហេតុ នៃកិច្ចប្រជុំអន្តរគណៈកម្មការ ជាមួយក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យលើសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់ ។ |

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| + សមាជិក សមាជិកាព្រឹទ្ធសភាបាន ៖<br>- អញ្ជើញជួបសវនាការជាមួយនឹងរដ្ឋបាលខេត្ត ថ្នាក់ដឹកនាំមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍសេដ្ឋកិច្ច និងការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ នៅខេត្តបាត់ដំបង<br>- អញ្ជើញចុះទៅសិក្សាឈ្វេងយល់ពីការប្រែប្រួលជាវិជ្ជមានក្រោយពេលរៀបចំវេទិកាបូកសរុបថ្នាក់ភូមិភាគ នាពេលកន្លងមក នៅខេត្តឧត្តរមានជ័យ<br>- អញ្ជើញចុះទៅប្រមូល និងផ្តល់ព័ត៌មានដើម្បីត្រៀមលក្ខណៈសម្រាប់គណៈប្រតិភូគណៈកម្មការទី៦ ព្រឹទ្ធសភាអញ្ជើញទៅបំពេញការងារ នៅខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ។ | - បានសម្រួលបែបបទ និងអមដំណើរបេសកកម្មគណៈកម្មការទី២ ចុះបេសកកម្មទៅខេត្តបាត់ដំបង ខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យចំនួន០៣លើក<br>- បានសម្រួលបែបបទបើកថវិកា និងធ្វើរបាយការណ៍ទូទាត់ចំណូល ចំណាយថវិកាប្រចាំខែជូនគណៈកម្មការនានា<br>- បានថត និងផ្សព្វផ្សាយព័ត៌មានសកម្មភាព៖<br>· គណៈទី១ ទី៤ ទី៧ និងទី១០ បើកកិច្ចប្រជុំផ្ទៃក្នុងចំនួន១០លើក ក្រុមសមាជិកព្រឹទ្ធសភា<br>· ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ រៀបចំវេទិកាថ្នាក់ស្រុកចំនួន០២លើក<br>· គណៈកម្មការទី២ និងទី៨ ប្រជុំពិនិត្យសេចក្តីព្រាងច្បាប់ជាមួយតំណាងរាជរដ្ឋាភិបាលចំនួន០២លើក<br>- ថតចម្លងឯកសារ សរុបចំនួន១៥សំណើ (១.៥៦៩ច្បាប់) អស់ក្រដាសសរុបចំនួន១៨.២៧៦ សន្លឹក។ |

៣.មុខងារតំណាង :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាបានៈ<br>+ អញ្ជើញដាក់កម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ<br>+ អញ្ជើញចូលរួមព្រះរាជពិធីរាប់បាត្រឧទ្ទិសព្រះរាជកុសលថ្វាយព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងបរិវេណព្រះឧបោសថរតនារាមព្រះកែវមរកត<br>+ អញ្ជើញចូលរួមពិធីប្រទានភ្លើងជ័យ និងពន្លត់ភ្លើងជ័យ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា<br>+ អញ្ជើញជាអធិបតីក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូន ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>+ អញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ បងប្អូនប្រជាកសិករ មេឃុំ មេភូមិ ថ្នាក់ដឹកនាំ លោកសាស្ត្រាចារ្យ និង | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាអធិបតីភាព ក្នុងពិធីផ្សេងៗ<br>- បានសហការរៀបចំវេទិកា ស្តីពីការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងភូមិ-ឃុំ មានសុវត្ថិភាព នៅខេត្តកំពង់ចាម<br>- បានធ្វើកំណត់បង្ហាញ និងបញ្ជូនពាក្យបណ្តឹងទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន ០៨ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន៣០ករណី<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនង ចុះស្រាវជ្រាវព័ត៌មាន ចុះបេសកកម្មរៀបចំវេទិកា ចុះតាមដានលទ្ធផលក្រោយការរៀបចំវេទិកា និងពិធីសំណេះសំណាលផ្សេងៗ អមដំណើរក្រុមសមាជិកា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ទី២ និងទី៤ ចំនួន០៧លើក<br>- បានសម្រួលបែបបទបើកថវិកា និងធ្វើរបាយការណ៍ទូទាត់ចំណូល ចំណាយថវិកាប្រចាំខែជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង ៨ និងក្រុមសមាជិកព្រឹទ្ធសភា។<br>- ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន និងនាយកដ្ឋាន បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការសហប្រតិបត្តិជាតិ និងកិច្ចប្រជុំក្រុមប្រឹក្សា នៅខេត្តរតនគិរី<br>- បានរៀបចំមាតិកា និង Upload រូបភាពសកម្ម |

| | |
|---|---|
| បុគ្គលិកសិក្សា នៅវិទ្យាល័យបាក់ទូក គណៈកម្មការកសាងទ្រទ្រង់ភូមិ កីឡាការីនី និងលេងកូនត្រីក្នុងអូរធម្មជាតិ ព្រមទាំងចូលរួមរំលែកទុក្ខក្រុមគ្រួសារសពចំនួន០៧លើក នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ ព្រមទាំងបានឧបត្ថម្ភថវិកាចំនួន ១០៥០ដុល្លារ សម្រាប់ការចាក់បង្ហើយផ្លូវបេតុងប្រវែង១៣៥០ម៉ែត្រ ស្ថិតនៅក្នុងភូមិស្វាយឧត្តម ស្រុកអង្គស្នួល ខេត្តកណ្តាល និងឧបត្ថម្ភថវិកាចំនួន១០លានរៀលសម្រាប់ជូនលោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកសិក្សា ជាការលើកទឹកចិត្តចំពោះការខិតខំបង្រៀនសិស្សទទួលបានលទ្ធផលល្អ ក្នុងឆ្នាំសិក្សា២០១៦ នៅវិទ្យាល័យបាក់ទូក<br>+បានឧបត្ថម្ភដល់ទូកដែលចូលរួមប្រណាំងចំនួន២៥៧ទូក ដោយទូកនីមួយៗទទួលបានទឹកប្រាក់ចំនួន៤០០.០០០រៀល និងឧបត្ថម្ភដល់គណៈកម្មការនានាបំរើការក្នុងព្រះរាជពិធីបុណ្យអុំទូកចំនួន១១៧.៨០០.០០០រៀល<br>+ អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ និងជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ព្រមទាំងចែកសម្ភារៈសង្គ្រោះបឋមដល់អនុវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែនពាមរាំង នៅស្រុកលើកដែក ខេត្តកណ្តាល<br>+អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះ | ភាពការងារដឹកនាំលើគេហទំព័រព្រឹទ្ធសភាចំនួន ៨៩ចំណងជើង<br>- ចងក្រងព័ត៌មានភូមិភាគទាំង៨ ផលិតជាCD អស់ចំនួន២១បន្ទះ ថត និងផ្សព្វផ្សាយព័ត៌មានចំនួន៩១លើក<br>- បានចុះសួរសុខទុក្ខមន្ត្រីលំហែមាតុភាព និងនិវត្តន៍ជន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៦នាក់<br>- រៀបចំសម្អាត តុបតែងកន្លែងប្រារព្ធពិធី បម្រើភេសជ្ជៈចំនួន០១លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៨៥នាក់ ស្មើនឹង៤៣ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០៨នាក់ ស្មើនឹង០៨ច្បាប់<br>- បានថតចម្លងឯកសារជូនគ្រប់អង្គភាពផ្សេងៗបានចំនួន១២សំណើ អស់ក្រដាសចំនួន៣.២០៣សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងរាជធានី និងតាមបណ្តាខេត្តក្រុងទាំង៨ភូមិភាគចំនួន១៦៦នាក់ ស្មើនឹង២៥លើក និងទូទាត់ការជួសជុលរថយន្តចំនួន១៧លើក<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៩៩លើកព្រមទាំងទូទាត់ថ្លៃអាហារសម្រន់ចំនួន០៤លើក |

| | |
|---|---|
| សំណាលជាមួយក្រុមប្រឹក្សាឃុំ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធទូទាំងខេត្តកណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នៅខេត្តកណ្តាល<br>+ អញ្ជើញដឹកនាំដង្ហែអង្គកឋិនទានព្រឹទ្ធសភា ទៅកាន់វត្តមុនីប្រសិទ្ធិវង្ស នៅរាជធានីភ្នំពេញ និងវត្តប្រាំបីមុំ ខេត្តតាកែវ<br>+ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាចូលរួមគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ទិត រាម** អតីតសមាជិកព្រឹទ្ធសភា នៅខេត្តកំពង់ចាម<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ទី២ និងទី៤ ផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ចំនួន០៧លើក នៅសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និងបានចុះតាមដានឈ្វេងយល់ពីវឌ្ឍនភាព ក្រោយរៀបចំវេទិកា នៅខេត្តព្រៃវែង ប៉ៃលិន ឧត្តរមានជ័យ និងខេត្តកំពង់ចាម<br>- អញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តបាត់ដំបង ខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំង<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានរៀបចំវេទិកាថ្នាក់ខណ្ឌ និង ស្រុក ស្តីពីការលើកកម្ពស់ការផ្តល់សេវាសាធារណៈ | និងថ្ងៃទិញសម្ភារៈ០៥លើក<br>- ទទួលលិខិតចូល និងឯកសារផ្សេងៗពីខាងក្រៅស្ថាប័នចំនួន ៦០៤ ច្បាប់ និងព្រមទាំងបានបញ្ជូនឯកសារផ្សេងៗទៅក្រៅស្ថាប័នចំនួន១១០ច្បាប់<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងពិធីផ្សេងៗចំនួន១៥នាក់ ស្មើនឹង០៣លើក<br>- ផ្តល់រូបថតចំនួន១.២៤០សន្លឹក និងអត្ថបទសារព័ត៌មានចំនួន១៣៥អត្ថបទ ជូនខុទ្ទកាល័យ និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ទទួលដំណើរទស្សនកិច្ចរបស់ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត មកពីសាកលវិទ្យាល័យនានាចំនួន ០១លើក ចំនួន ១៥នាក់<br>- ទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន២០៤នាក់ ធ្វើប័ណ្ណសមាជិកចំនួន១៣នាក់ ខ្ចីសៀវភៅចំនួន៤២ក្បាល និងសងវិញចំនួន៤៧ក្បាល<br>- ទទួលឯកសារ សៀវភៅ ព្រឹត្តិបត្រ ទស្សនាវដ្តី និងកាសែតពីអង្គការ ស្ថានទូត ស្ថាប័ន ក្រសួង គ្រឹះស្ថានអប់រំ សប្បុរសជន នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៦១២ក្បាល និង៥៨ច្បាប់<br>- ចុះលេខចុងសន្លឹក សរសេរមាតិកាលិខិត រៀបចំឯកសាររបស់ថ្នាក់ដឹកនាំ គណៈកម្មការទាំង ១០ និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២០ប្រអប់ និង៥៥៥សំណុំ<br>- សម្របសម្រួល និងទទួលដំណើរទស្សនកិច្ចសិក្សា |

| | |
|---|---|
| និងភូមិ-ឃុំ មានសុវត្ថិភាព នៅខេត្តកំពង់ចាម<br>- បានទទួលពាក្យបណ្ដឹងពីប្រជាពលរដ្ឋ ចំនួន០៨ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្ដាខេត្ត រាជធានី ទូទាំងប្រទេស ចំនួន១៦១លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ពិសេសផ្សព្វផ្សាយ និងជំរុញប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត និងការធ្វើអត្ត-សញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មី ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ។ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការផ្សេងៗសរុបចំនួន៨៦លើក ។ | លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស មកពីសាលាអន្តរជាតិអាប៊ែនឌែនឡៃចំនួន០១លើក អ្នកចូលរួមចំនួន១៤រូប<br>- កត់ត្រាសិស្ស និស្សិតចូលអានសៀវភៅនៅបណ្ណាល័យចំនួន១៥២នាក់ ភ្ញៀវមកទំនាក់ទំនងការងារនៅក្នុងព្រឹទ្ធសភាចំនួន៤៩នាក់ មន្ត្រីចេញចូលថ្ងៃឈប់សម្រាកចំនួន២៧២នាក់ ។ |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា អនុញ្ញាតឲ្យប្រធានរដ្ឋសភាឡាវ ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអង្គការអន្តរជាតិនានា |

| | |
|---|---|
| នៃសាធារណរដ្ឋអាល្លឺម៉ង់ប្រធានព្រឹទ្ធសភា នៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថានចូលជួប សម្តែងការគួរសម និងសវនាការ<br>- សមាជិកព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយនាយិកានៃអង្គការ Habitat for Humanity ប្រចាំកម្ពុជាលើគម្រោងកម្មវិធីលំនៅដ្ឋានសម្រាប់សហគមន៍ក្រីក្រ និងអ្នកមានចំណូលទាប<br>- សមាជិកព្រឹទ្ធសភាជួបប្រជុំពិភាក្សាការងារជាមួយគណៈប្រតិភូស្ថានទូតជប៉ុន និងគណៈប្រតិភូកូរ៉េ<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញទៅបំពេញទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរបទពិសោធន៍ការងារ នៅសាធារណរដ្ឋបារាំង សាធារណរដ្ឋសង្គមនិយមវៀតណាម លុចហ្សំបួរ អូស្ត្រាលី កិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក (ASGP) នៅប្រទេសស្វីស មហាសន្និបាតលើកទី១៨ នៃសន្និសីទសភាអាស៊ីប៉ាស៊ីហ្វិចលើកទី១៨ (APPCED) ស្តីពី បរិស្ថាន និងការអភិវឌ្ឍ នៅសាធារណរដ្ឋកូរ៉េ សន្និសីទនៅតំបន់អាស៊ីអាគ្នេយ៍ដើម្បីមនុស្សធម៌ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងវេទិកាសមាជិកអាស៊ី-ប៉ាស៊ីហ្វិកស្តីពី សុខភាពសកលលោក នៅសាធារណរដ្ឋកូរ៉េ<br>- គណៈប្រតិភូព្រឹទ្ធសភា បានអញ្ជើញចូលរួមសហការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី១ និងមហាសន្និបាតលើកទី៩ របស់ | - បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់ស្តីពីការលើកកម្ពស់កិច្ចសហប្រតិបត្តិការសភាជាមួយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប៉ាគីស្ថាន នៅប្រទេសប៉ាគីស្ថាន<br>- ឯកឧត្តមអគ្គលេខាធិការ អនុញ្ញាតឲ្យឯកអគ្គរដ្ឋទូតរុស្ស៊ីប្រចាំនៅកម្ពុជា តំណាងអង្គការ SES ប្រចាំកម្ពុជា នាយកវិទ្យាស្ថានសភាកម្ពុជា (PIC) និងមន្ត្រីដែលទើបទទួលសញ្ញាបត្រថ្មីចំនួន០៤ នាក់ចូលជួបពិភាក្សាការងារ<br>- រៀបចំទីកន្លែងសម្រាប់ជំនួបសម្តែងការគួរសម និងបដិសណ្ឋារកិច្ចចំនួន០៤លើក ។ ទំនាក់ទំនងជាមួយស្ថានទូតបណ្តាប្រទេសជាមិត្ត ដើម្បីសម្រួលបែបបទ កម្មវិធីទស្សនកិច្ច ធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត ជំនួយស្មារតី បើកបន្ទប់VIP អាកាសយានដ្ឋានអន្តរជាតិភ្នំពេញជូន និងទទួលដំណើរបេសកកម្មសរុបចំនួន៣៧លើក<br>- ពន្យាទិដ្ឋាការ និងធ្វើលិខិតឆ្លងដែនការទូតថ្មីចំនួន១១សៀវភៅ<br>- រៀបចំសម្អាត តុបតែងសាល ផ្តល់សេវាផ្គត់ផ្គង់សម្ភារ ភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗ ចំនួន០៥លើក អ្នកចូលរួមចំនួន១៧៣នាក់<br>- ថតចម្លងឯកសារ និងចងក្រងធ្វើសៀវភៅចំនួន ០៣សំណើ(៤២៥ច្បាប់) អស់ក្រដាសចំនួន ៤៦.២៥៥សន្លឹក<br>- ផ្តល់សេវាថវិកាសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា |

| | |
|---|---|
| សភាតំបន់អាស៊ី(APA) នៅខេត្តសៀមរាប។ | ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ថ្លៃចំណាយផ្សេងៗសរុប ចំនួន១៥លើក<br>- ផ្តល់សេវាដឹកជញ្ជូនជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងរាជធានីចំនួន១០នាក់ ស្មើនឹង០២លើក<br>- បង្ហោះកម្មវិធីលើទូរទស្សន៍នៅតាមអគារ E, F, G,ចំនួន១៨លើក លើបណ្តាញសង្គម Facebook ចំនួន១៥៧លើក តាមស្ថានីយ៍ទូរទស្សន៍ចំនួន ១២លើក<br>- បន្តទំនាក់ទំនងដើម្បីពង្រឹងកិច្ចសហប្រតិការជាមួយដៃគូជាតិ អន្តរជាតិ ផ្លាស់ប្តូរបទពិសោធន៍ទស្សនកិច្ចសិក្សាលើជំនាញ IT ជំនាញបណ្ណាល័យ និងភាសាអង់គ្លេសសម្រាប់មន្ត្រីរាជការ<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៧ច្បាប់(ចំនួន១៩នាក់)<br>- បញ្ជូនលិខិតទៅក្រៅស្ថាប័នព្រឹទ្ធសភាចំនួន ១០១ច្បាប់<br>- ការពារសន្តិសុខ សុវត្ថិភាព រៀបចំសណ្តាប់ធ្នាប់ដោយប្រើប្រាស់កម្លាំងសរុបចំនួន៥៥នាក់ ស្មើនឹង០១លើក<br>- សហការជាមួយអង្គការមូលនិធិ Max Planck អន្តរជាតិ, ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ KOICA រៀបចំសិក្ខាសាលាស្តីពី " តុលាការអន្តរជាតិ និងសាលាជម្រះក្តី"<br>- ទំនាក់ទំនងជាមួយស្ថានទូតបារាំង សភារ៉ូឡូនីព្រុចសែល ប៊ែលហ្ស៊ិក ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |

| | |
|---|---|
| | សមាគមអគ្គលេខាធិការនិយាយភាសាបារាំង សង្គមស៊ីវិល ក្រសួងនិងស្ថាប័ននានា សម្រាប់ដំណើរទស្សនកិច្ច សិក្ខាសាលា និងបំពេញបេសកកម្មក្នុង និងក្រៅប្រទេស និងការរៀបចំពិធីផ្សេងៗ<br>- ថ្នាក់ដឹកនាំអគ្គលេខាធិការ អគ្គនាយកដ្ឋាន និងនាយកដ្ឋាន បានទៅចូលរួមសិក្ខាសាលាលើកទី២ របស់ក្រុមការងារស្រាវជ្រាវ និងសន្និសីទប្រចាំឆ្នាំរបស់ KPI ក្នុងក្របខ័ណ្ឌ នៃការអនុវត្តគម្រោងស្រាវជ្រាវរួមគ្នា នៅប្រទេសថៃឡង់ដ៍ និងបានទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន សាធារណរដ្ឋកូរ៉េ វៀតណាម អូស្ត្រាលី ស្វីស និងសាធារណរដ្ឋប្រជាមានិតចិន ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ព្រឹទ្ធសភាកំពុងដំណើរការសាងសង់អគារការិយាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា ជាជំនួយរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន<br>និងតាមដានគម្រោងស្នើសុំសាងសង់អគារសាលប្រជុំពេញអង្គថ្មីជាមួយស្ថាប័នពាក់ព័ន្ធ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថានទូតចិន)<br>- សហប្រតិបត្តិការជាមួយដៃគូដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ស្ថាប័ន ។ | - បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៤៤ច្បាប់<br>- ប្រជុំធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ១០ឆ្នាំរបស់អគ្គនាយកដ្ឋាន និងប្រជុំការងារផ្ទៃក្នុងអគ្គនាយកដ្ឋានជាមួយថ្នាក់ដឹកនាំនាយកដ្ឋាន ដើម្បីលើកទិសដៅការងារអនុវត្តនៅពេលខាងមុខ<br>- រៀបចំចងក្រងបទបង្ហាញស្តីពីលទ្ធផលការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០១៦ និងរបាយការណ៍ស្តីពីលទ្ធផលការងាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រង់ស្ថិតិស្តីពីលទ្ធផលការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកា |

| | |
|---|---|
| | គណៈកម្មការជំនាញទាំង១០ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែវិច្ឆិកា ឆ្នាំ២០១៦ ព្រមទាំង បានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះ សរុបចំនួន២៧០ច្បាប់<br>- បានកំពុងបន្តសិក្សាស្រាវជ្រាវលើប្រធានបទសំខាន់ៗ ពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័ន ចំនួន០១ច្បាប់ និងបានស្រាវជ្រាវ និងសង្ខេបព័ត៌មានប្រចាំថ្ងៃអំពីសភាប្រទេសនានា<br>- បញ្ចូលទិន្នន័យសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងព្រឹទ្ធសភា និងកាលប្បវត្តិ-ឯកសារទៅក្នុងប្រព័ន្ធកុំព្យូទ័រ ។<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- បានធ្វើលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៣៨ច្បាប់ និង៤០ ប័ណ្ណ<br>- ប្រជុំអន្តរគណៈកម្មការពាក់ព័ន្ធនឹងវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ និងបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ច អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំគណៈកម្មការរៀបចំ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំអន្តរគណៈកម្មការត្រួតពិនិត្យ និងកែសម្រួលសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការគ្រប់គ្រងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលទៅសិក្សាក្រៅប្រទេស<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស:<br>- បណ្តុះបណ្តាលធនធានមនុស្សនៅក្នុង-ក្រៅ |

ស្ថាប័នចំនួន០៦វគ្គ មានសិក្ខាកាមសរុបចំនួន៦៦នាក់ និងវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន០១វគ្គ មានសិក្ខាកាមចំនួន០១នាក់ ព្រមទាំងទស្សនកិច្ចសិក្សាក្រៅប្រទេសចំនួន០១វគ្គ សិក្ខាកាមចំនួន០៣នាក់

- កសាងផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រយៈពេល០៥ឆ្នាំ (២០១៧-២០២២)។

+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ :

- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែវិច្ឆិកា ឆ្នាំ២០១៦ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានបើកប្រាក់បៀវត្ស ប្រាក់បេសកកម្ម ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការបានទាន់ពេលវេលា
- ទូទាត់ថ្លៃទិញសម្ភារៈ គ្រឿងអេឡិចត្រូនិច ជួសជុលសម្ភារៈឧបករណ៍បច្ចេកទេសផ្សេងៗ ជួសជុលរថយន្ត កែលម្អសោភ័ណ្ឌភាពសួនច្បារ អគារ សាលប្រជុំ ផ្លូវថ្នល់នៅក្នុងបរិវេណព្រឹទ្ធសភា និងទូទាត់ការបោះពុម្ពសៀវភៅ និងឯកសារផ្សេងៗចំនួន៥០លើក
- បានលើកគម្រោងទិញវត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំ

| | |
|---|---|
| | និងសិក្ខាសាលាចំនួន២៨សំណើ ព្រមទាំងបាន ប្រគល់ និងទទួលសម្ភារផ្សេងៗចំនួន០៩សំណើ ផ្គត់ផ្គង់សម្ភារអនាម័យ ការិយាល័យ និងភេសជ្ជៈ ចំនួន៣២សំណើ ជូនគ្រប់អង្គភាពចំណុះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល និងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងពិធីផ្សេងៗចំនួន១០លើក មានអ្នកចូលរួមចំនួន៣៥៩នាក់<br>- ទូទាត់ថ្លៃលទ្ធកម្ម ទិញប្រេងឥន្ធនៈ សម្ភារៈការិយាល័យ សម្ភារៈអនាម័យ បោះពុម្ពព្រឹត្តិបត្រ ប្រតិទិនប្រចាំឆ្នាំ សៀវភៅទិនានុលេខន៍ និងសម្ភារៈផ្សេងៗចំនួន១០លើក<br>- ផ្តល់សេវាថវិកា សម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីអគ្គលេខាធិការដ្ឋាន និងទូទាត់ការចំណាយផ្សេងៗចំនួន៧៧លើក<br>- ថតចម្លងឯកសារ និងរៀបចំចងក្រងធ្វើជាសៀវភៅចំនួន៥៧សំណើ(១៣.៨៤២ច្បាប់) ធ្វើសៀវភៅ៣០ក្បាល អស់ក្រដាសចំនួន ៣៤.៥០០សន្លឹក និងជួសជុល លាងសម្អាតម៉ាស៊ីនថតចម្លងចំនួន១០លើក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភានិងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅតាមបណ្តាខេត្ត-ក្រុងរាជធានីទាំង៨ភូមិភាគចំនួន៦០លើក អ្នកចូលរួម ២៤២ នាក់ ។<br>+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រឹង និងទន់: |

| | |
|---|---|
| | - ចូលរួមត្រួតពិនិត្យការដ្ឋានសាងសង់អគារការិយាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា<br>- ជួសជុល និងតម្លើងតុឈើបេងនៅសាលសាឡុងធំ សាលពិសេសកណ្ដាល និងសាលបណ្ណាល័យ ចំនួន០៥គ្រឿង<br>- កាត់តម្រឹមស្មៅ ផ្កា ថែទាំដាក់ជី ដាំដើមឈើផ្សេងៗ ព្រមទាំងថែទាំសួនច្បារនានា ឲ្យមានសោភ័ណ្ឌភាពល្អ<br>- សហការចុះត្រួតពិនិត្យសត្វកណ្ដៀរ នៅសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ សាលប្រជុំពេញអង្គ ការិយាល័យអគ្គលេខាធិការ និងអគារB<br>- ជួសជុល និងផ្លាស់ប្ដូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិចសរុបចំនួន៩២គ្រឿង ជួសជុលបណ្ដាញទឹកចំនួន០៣ខ្សែ និងជួសជុលកែលម្អបន្ទប់ទឹកនៅខាងក្រោយសាលពិសេស និងស្ពានប្រព័ន្ធលូនៅខាងមុខសាលបណ្ណាល័យ<br>- បិទលេខកូដមាន ក្បាល DVD ទូរទស្សន៍ ទូកង្ហារ បាញ់ខ្យល់ និងម៉ាស៊ីនកាត់ក្រដាសចំនួន០៥គ្រឿង<br>- សហការរៀបចំ និងប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំចំនួន២០លើក<br>- ផ្ដល់សេវា Network, Internet, Connect Wifi ជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus និងបញ្ចូលកម្មវិធី Unicode សរុបចំនួន៦៥គ្រឿង<br>- សង់ឃ្លាំងប្រក់ដំបូលស័ង្កសីដាក់សម្ភារនៅក្រោយអគារ D និងសម្អាតដំបូល ទទឹក លាបថ្នាំ |

| | |
|---|---|
| | ការពារទឹកជ្រាបនៅអគារក្រហម សាលពិសេស<br>ធំ និងសាលខាងជើង ព្រមទាំងរៀបជញ្ជាំងថ្មភ្នំ<br>នៅមុខនាយកដ្ឋានរដ្ឋបាល និងរៀបខឿនថ្មល់ថ្ម<br>ម៉ាបនៅខាងមុខអគារក្រុមប្រឹក្សាជម្មនុញ្ញ និង<br>ចាប់ពី P2 រហូតដល់អគារក្រហម ។<br>+ការងារផ្សេងៗ:<br>- បានសហការចូលរួមរៀបចំពិធីបំពាក់គ្រឿង<br>ឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការ<br>ដ្ឋានព្រឹទ្ធសភា ដែលមានស្នាដៃ សម្រាប់ឆ្នាំ២០១៥<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុង<br>កម្មវិធីផ្សេងៗចំនួន២៤លើក អស់កាសែត១៥<br>ដុំ DVD និងMP3 ចំនួន៤០បន្ទះ<br>- បង្ហោះរបាយការណ៍លទ្ធផលការងារ និងរូបថត<br>សកម្មភាពរបស់ថ្នាក់ដឹកនាំក្នុងកិច្ចប្រជុំផ្សេងៗ<br>ចំនួន០៦ចំណាងជើង ។ ស្កេន ពិនិត្យអក្ខរាវិរុទ្ធ<br>តម្លើងប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាល និងដាក់<br>កម្មវិធី software Check List<br>- ប្រគល់វិញ្ញាបនប័ត្របញ្ចប់វគ្គបណ្តុះបណ្តាលការងារ<br>បណ្ណាល័យដល់និស្សិត មកពីសហព័ន្ធយុវជន<br>សង្កាត់ព្រែកតាសេកចំនួន០៥នាក់ និងបណ្ណារក្ស<br>ព្រឹទ្ធសភាចំនួន០៤នាក់<br>- ចងក្រងសៀវភៅអង់គ្លេស ច្បាប់ កាសែត ទស្សនាវដ្តី<br>ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី<br>បញ្ចូលសៀវភៅតាម PMB និង E-Library សរុប<br>ចំនួន៦.០៧៧ក្បាល ដែលមានអ្នកចូលអាន<br>៣.២៦៦នាក់<br>- ការពារ និងរៀបចំសណ្តាប់ធ្នាប់រថយន្តគ្រប់ប្រភេទ<br>នៅក្នុងបរិវេណព្រឹទ្ធសភាបានចំនួន២១លើក។ |

## II.ទិសដៅការងារខែធ្នូ ឆ្នាំ២០១៦

### ១.មុខងារនីតិកម្ម:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៣ ៖

+ សេចក្តីព្រាងច្បាប់ ស្តីពីការប្រែប្រួលធាតុអាកាស

+ សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៧

+ សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាជាតិឆ្នាំ២០១៥

-ត្រៀមបន្តនីតិវិធីពាក់ព័ន្ធច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាក់តែង និង ពិគ្រោះយោបល់អំពីសេចក្តីព្រាងក្រមសីលធម៌ និងបទបញ្ជាផ្ទៃក្នុងថ្មី។

### ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការ ចុះបេសកកម្មតាមបណ្តាខេត្ត-ក្រុង ។

### ៣.មុខងារតំណាង :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានានៅរាជធានីភ្នំពេញ និង តាមបណ្តាខេត្ត ក្រុង

-ត្រៀមរៀបចំវេទិកាតាមភូមិភាគទាំង៨ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមចូលរួមប្រារព្ធទិវាសិទ្ធមនុស្ស (៩ ខែធ្នូ) និងពិធីបុណ្យរំលឹកខួបគុណសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម និងលោកជំទាវ

### ៤.កិច្ចសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា ព្រមទាំង ពិធីទទួលសារតាំងទូតថ្មី ៖

-ឯកអគ្គរាជរដ្ឋទូតជប៉ុន

-គណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភាប៉ូឡូញ (ខែមករា ២០១៧)

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា៖ ASGPF, SES, CIM, KAS, GIZ, MAX PLANCK FOUNDATION, UNESCO និង KOICA

-ត្រៀមរៀបចំកម្មវិធីសហប្រតិបត្តិការជាមួយ KAS, GIZ និង ស្ថានទូតអាល្លឺម៉ង់ (ថ្ងៃទី៩ ខែធ្នូ ២០១៦)

-រៀបចំការបណ្តុះបណ្តាល PBO និងទំនាក់ទំនងជាមួយលេខាធិការដ្ឋាន APF អំពីកិច្ចសហប្រតិបត្តិការបច្ចេកទេស

-បញ្ជូនមន្ត្រីចំនួន ០៧រូប ចូលរួមសន្និបាតវិទ្យាស្ថានKPI នៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៍

-សហប្រតិបត្តិការតំបន់ (ត្បូង-ត្បូង) តាមរយៈកម្មវិធីបណ្តុះបណ្តាលខាងការស្រាវជ្រាវ និងការរៀបចំ MOU សហប្រតិបត្តិការជាមួយវិទ្យាស្ថានស្រាវជ្រាវសភា ឥណ្ឌា និងប៉ាគីស្ថាន ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ច អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ តាមប្រព័ន្ធព័ត៌មានវិទ្យាកសាង Program និង Software ដើម្បីអនុវត្តន៍តាមអង្គភាព និងការបណ្តុះបណ្តាល ក្នុងនោះការអនុវត្តកម្មវិធី E-បណ្ណាល័យ និង E-បណ្ណសារ

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រកត កូរ៉េ ជប៉ុន ចិន ឥណ្ឌា អូស្ត្រាលី នូវែលហ្សេឡង់ សិង្ហបុរី ថៃ ម៉ាឡេស៊ី

-ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តជាក់ស្តែង

-ការរៀបចំបែងចែកគម្រោងថវិកាឆ្នាំ២០១៧ សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល

-ការត្រៀមរបាយការណ៍ចំណូល - ចំណាយថវិកាឆ្នាំ២០១៦ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ជប៉ុន ឥណ្ឌា និងការបំពាក់សម្ភារបរិក្ខារ ICT ជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ដំណាក់កាលទី២

-ការសិក្សារៀបចំ TV - online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-បន្តប្រជុំគណៈកម្មការពិនិត្យ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តប្រជុំអន្តរគណៈកម្មការពាក់ព័ន្ធនឹងវិសោធនកម្មច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិបញ្ញត្តិ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិបំរើឲ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

- ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធនធានមនុស្ស

- កសាងបង្គន់អគារសាលប្រជុំចាស់ ថ្មី និងការរៀបចំជុំវិញបរិវេណអគារការិយាល័យថ្នាក់ដឹកនាំព្រមទាំងត្រៀមឯកសារពាក់ព័ន្ធដល់ការសម្ពោធអគារ (ខែមករា ២០១៧)

-ត្រៀមរបាយការណ៍បូកសរុបបំណាច់ឆ្នាំ រៀបចំផែនការប្រតិបត្តិឆ្នាំ២០១៧ បច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ១០ឆ្នាំ រៀបចំផែនការថវិកាតាមកម្មវិធីសម្រាប់ឆ្នាំ២០១៧ បច្ចុប្បន្នភាពលើមូលដ្ឋានគោលការណ៍ ៣ E's ទ្រព្យសម្បត្តិ ធនធានមនុស្ស និងតម្រូវការ ។

III.**សេចក្តីសន្និដ្ឋាន**

ក្នុងខែវិច្ឆិកានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមពិធីថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបរមរតនកោដ្ឋ និងពិធីប្រទានភ្លើងជ័យ ទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា រួមទាំងពិធីផ្សេងៗទៀតជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបានយ៉ាងល្អប្រសើរ ។ ជាមួយគ្នានេះ បានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម បានចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០២លើក និងបានចាត់ចែងប្រជុំពិនិត្យលើសេចក្តីព្រាងផ្សេងៗចំនួន០៥ច្បាប់ ។ ចំពោះមុខងារតាមដានការអនុវត្តច្បាប់ បានចុះតាមដានប្រមូលព័ត៌មាន នៅខេត្តបាត់ដំបង ។ ដោយឡែក លើមុខងារតំណាង បានចាត់ចែងកម្មវិធីចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ មេឃុំ កីឡាការនី និងលែងកូនត្រីក្នុងអូរធម្មជាតិ ព្រមទាំងចូលរួមគោរពវិញ្ញាណក្ខន្ធសព និងពិធីផ្សេងៗទៀត នៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ បាត់ដំបង កំពង់ធំ និងខេត្តកំពង់ឆ្នាំង។ល។ ការអភិវឌ្ឍស្ថាប័នបានឆ្លុះបញ្ចាំងឲ្យឃើញនូវការអភិវឌ្ឍធនធានមនុស្ស ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ការកសាងអគារ និងហេដ្ឋារចនាសម្ព័ន្ធមានការរីកចម្រើន ។ ការងារកិច្ចសហប្រតិបត្តិការការអន្តរជាតិបានបន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់ព្រឹទ្ធសភាតាមរយៈវិទ្យាស្ថានសភាកម្ពុជា (PIC) និងដៃគូអភិវឌ្ឍន៍នានា។ ទន្ទឹមនេះ អគ្គលេខាធិការបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយនឹងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប៉ាគីស្ថាន ដែលបើកផ្លូវដល់កិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា (PIC) វិទ្យាស្ថានPIPS និងវិទ្យាស្ថានស្រាវជ្រាវសភាឥណ្ឌា ។

ភ្នំពេញ,ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ